ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ
Khmer Movement For Democracy
Organize the Movement * Educate the Public * Mobilize the People

០៨ កុម្ភៈ ២០២៥

# សេចក្ដីថ្លែងការណ៍

ចលនាខ្មែរដើម្បីប្រជាធិតេយ្យ (KMD) មានគោលដៅជាក់លាក់ដើម្បីផ្លាស់ប្ដូរស្ថានភាពកម្ពុជាបច្ចុប្បន្ន ទៅកាន់ប្រព័ន្ធដឹកនាំបែបប្រជាធិបតេយ្យសេរីពហុបក្ស ដែលប្រជាពលរដ្ឋខ្មែរ ជាម្ចាស់សិទ្ធិស្វ័យសម្រេចវាសនាជាតិ។ យើងដាក់កម្មវត្ថុអាទិភាព នៃការសម្រេចឲ្យបាន នៅថ្ងៃអនាគត នូវប្រទេសកម្ពុជា ដែលត្រូវរៀបចំការបោះឆ្នោត ដោយសេរី បើកចំហ អហិង្សា ត្រឹមត្រូវ និង យុត្តិធម៌ ស្របតាមឆន្ទៈ របស់ប្រជាពលរដ្ឋខ្មែរ ដូចមានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ និង រដ្ឋធម្មនុញ្ញកម្ពុជា។

ដើម្បីសម្រេចគោលដៅ និង មានឱកាសអនុវត្តន៍កម្មវត្ថុអាទិភាព ក្នុងបុព្វហេតុប្រយោជន៍ប្រជាពលរដ្ឋ និងប្រទេសកម្ពុជានេះ យើងប្រកាន់ខ្ជាប់ និង បដិបត្តិយ៉ាងម៉ឺងម៉ាត់ នូវជំហរការពារយុត្តិធម៌ និង ការផ្សះផ្សាបង្រួបបង្រួមអ្នកប្រជាធិបតេយ្យ ដោយសុចរិត។ ជំហរ និង ការបដិបត្តិនេះ គឺជាវិន័យការងាររួម ក្នុងប្រព័ន្ធដឹកនាំគ្រប់លំដាក់ថ្នាក់ នៃចលនាខ្មែរដើម្បីប្រជាធិតេយ្យ។

លើសពីនេះ យើងមានជំនឿដ៏មុតមាំថា ប្រជាពលរដ្ឋខ្មែរនឹងចូលរួមសហការជាមួយ ចលនាខ្មែរដើម្បីប្រជាធិតេយ្យ ដើម្បីយើងរួមគ្នាសម្រេចគោលដៅប្រជាធិបតេយ្យជាតិកម្ពុជា។ ប្រទេសជាតិកម្ពុជារបស់យើងកំពុងរង់ចាំឲ្យយើងជាខ្មែរគ្រប់មជ្ឈដ្ឋាន ដែលប្រាថ្នាប្រជាធិបតេយ្យ ចេះរួបរួមគ្នា សង្គ្រោះឲ្យទាន់ពេលវេលាតាមគោលការណ៍នៃការតម្កល់ផលប្រយោជន៍ជាតិជាធំ។

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ជនរួមជាតិខ្មែរទាំងក្នុង និងក្រៅប្រទេស សហគមន៍អន្តរជាតិ និងអង្គការដៃគូនានា ដែលគាំទ្រចលនាខ្មែរដើម្បីប្រជាធិតេយ្យ យ៉ាងសកម្ម។ ដោយមានការគាំទ្រទាំងនេះ ទើបយើងសម្រេចបានផ្លែផ្កាដ៏ត្រចះត្រចង់នាពេលកន្លងមក ដូចជា ភស្តុតាងនៃករណីCLV-DTA ជាដើម។ យើងក៏សង្ឃឹមថា យើងនឹងដណ្ដើមបានសមិទ្ធផលធំៗបន្ថែមទៀត ជាពិសេស ការនាំប្រជាធិបតេយ្យជូនប្រជាពលរដ្ឋខ្មែរ នៅក្នុងប្រទេស។

សុចរិត យុត្តិធម៌ និង ការផ្សះផ្សាបង្រួបបង្រួមអ្នកប្រជាធិបតេយ្យ គឺជាគោលការណ៍ផ្លូវបដិបត្តិរបស់យើង ទៅកាន់គោលដៅជោគជ័យប្រជាធិបតេយ្យ។

111 Fitchburg Rd, Ayer, MA 01432
contact@khmermovementfordemocracy.org
Khmermovementfordemocracy.org
+1 702 808 0337

N-O